# តើការសុខចិត្តចុះញ៉ម ទល់នឹង ធនក្ស័យ ឬ?

គ្មាននរណាម្នាក់ឡើយ – ទោះជាសមាជិកសហជីព ឬអ្នកតំណាងសហជីព – សប្បាយចិត្តអំពីការសុខចិត្តចុះញ៉ម Sky Chefs កាលពីខែមេសាកន្លងទៅឡើយ ។ ការកាត់បន្ថយទាំងនេះ គឺជាការឈឺចាប់ចំពោះកម្មករដែលបានប៉ះពាល់ ។ តែជាយ៉ាងណាមិញ កម្មករមួយចំនួនមិនសប្បាយចិត្តជាមួយនឹងវិធីដែលបានប្រើ នៅក្នុងការប៉ុនប៉ងរបស់ក្រុមហ៊ុន ដើម្បីឲ្យបានការសុខចិត្តចុះញ៉មឡើយ ។ វាគឺជាសារៈសំខាន់ណាស់ ដែលអ្នកគួរតែដឹង និងយល់អំពីហេតុការណ៍ពិត ។

**“ជាមួយនឹងការអនុញ្ញាតធនក្ស័យរបស់តុលាការ ក្រុមហ៊ុនអាកាសយាន Northwest មានគំនិតបន្ទាបប្រាក់ថ្លៃឈ្នួល និងអត្ថប្រយោជន៍របស់ខ្លួន ទៅលើអ្នកបំរើអាកាសចរណ៍ 7,300 នាក់ កាលពីខែកន្លងនៅនេះ” ។** Detroit Free Press, 9/16/06

កិច្ចសន្យារបស់ Sky Chefs គឺបានគ្រប់គ្រងដោយក្រឹត្យការងារផ្លូវរថភ្លើង ដែលជាច្បាប់ដូចគ្នាអនុវត្តទៅលើអ្នកធ្វើការក្នុងក្រុមហ៊ុនអាកាសយាន ដូចជាអ្នកបំរើអាកាសចរណ៍ Northwest Airlines ជាដើម ។ តែជាយ៉ាងណាមិញ វាមាន**ភាពខុសប្លែកគ្នាខ្លាំង** រវាងការសុខចិត្តចុះញ៉មនៅពេលថ្មីៗនៅ Sky Chefs និងអ្នកបំរើអាកាសចរណ៍ក្រុមហ៊ុនអាកាសយាន Northwest Airlines ទាំងអស់នោះ ។ អ្នកបំរើអាកាសចរណ៍ពុំអាចត្រួតត្រាបានទៅលើចំណែកអ្វីៗនៃប្រាក់ថ្លៃឈ្នួលរបស់គេ ដែលបានកាត់បន្ថយ ឬអត្ថប្រយោជន៍ដែលបានបញ្ចុះតម្លៃឡើយ ។ នោះគឺពីព្រោះតែ Northwest បានប្ដឹងសុំភាពការធនក្ស័យ(ការរលុំអស់ធនធាន) **ដែលអាចបណ្ដាលឲ្យមានការបំបាត់ចោលនូវអត្ថប្រយោជន៍ភាគច្រើន ឬទាំងអស់ នៅក្នុងកិច្ចសន្យាសហជីព ។** កម្មករពុំមានសំឡេងផ្ទាល់សោះ ក្នុងការបញ្ចុះតម្លៃអ្វីៗនៃការកាត់ក្ដីភាពធនក្ស័យ ។

Sky Chefs បានទាមទារការចុះញ៉មយ៉ាងច្រើន ក្នុងកិច្ចសន្យាសហជីព ដើម្បីឲ្យនៅក្រកួតប្រជែងបាន ជាមួយនឹងអ្នកផ្ដល់ម្ហូបឲ្យក្រុមហ៊ុនអាកាសយានផ្សេងទៀត រួមទាំងអ្នកផ្ដល់ម្ហូបឥតមានសហជីព ដែលបើកប្រាក់ថ្លៃឈ្នួលថោកបំផុត ទាំងគ្មានអត្ថប្រយោជន៍អ្វីសោះ ។

ការ**<u>បោះឆ្នោតដំបូង បានបរាជ័យដោយ 136</u>** សន្លឹកឆ្នោត ក្នុងបណ្ដា 5, 378 សន្លឹកឆ្នោតដែលបានបោះ - **50.9 %** ឥតបានបោះឆ្នោត ។ ថ្វីបើការបដិសេធន៍នោះ គឺគ្រាន់តែជិតពាក់កណ្ដាលនៃអស់អ្នកបានបោះឆ្នោតក៏ដោយ គង់តែក្រុមហ៊ុនបានប្រាប់មេធាវីរបស់គេ ឲ្យត្រៀមក្រដាសស្នាមដើម្បីប្ដឹងសុំភាពធនក្ស័យ ។ ទាំងនេះគឺពុំមែនជាការចរចាធម្មតាទេ ។ តែជាយ៉ាងណាមិញ សហជីពបានប្រឹងប្រែងជំរុញក្រុមហ៊ុនឲ្យកែការផ្ដល់ជូនរបស់គេឲ្យប្រសើរឡើង ប្រយោជន៍ឲ្យសមាជិករបស់យើងអាចបានសល់ពីភាពអាចបាត់បង់នូវអត្ថប្រយោជន៍ **ទាំងអស់** នៅក្នុងតុលាការធនក្ស័យ ។ **<u>ការផ្ដល់ជូនទីពីរនោះបានព្រមទទួលយក ដោយសន្លឹកឆ្នោតជាង 1,000 សន្លឹក</u>** ក្នុងបណ្ដា 5,479 សន្លឹកឆ្នោតដែលបានបោះ – **59.9% បានបោះ បាទ/ចាស** ជាមួយនឹងកម្មករដែលចូលរួមក្នុងការបោះឆ្នោត 100 នាក់ទៀត ។

សមាជិករបស់ UNITE HERE នៅទូទាំងប្រទេស បានមានឱកាសបោះឆ្នោត ក្នុងការបោះឆ្នោតជាប្រជាធិបតេយ្យ ថាតើព្រមទទួល ឬមិនព្រមទទួលនូវការសុខចិត្តចុះញ៉មបែបនេះ ។ អ្នកបំរើអាកាសចរណ៍ក្រុមហ៊ុនអាកាសយាន Northwest ពុំបានបោះឆ្នោតក្នុងការសុខចិត្តចុះញ៉មរបស់គេទេ ពីព្រោះតែក្រុមហ៊ុនបានប្ដឹងសុំភាពធនក្ស័យរួចទៅហើយ ។

វាអាចនឹងជាការមិនទទួលខុសត្រូវនៃសហជីពរបស់អ្នក ដោយបណ្ដោយឲ្យក្រុមហ៊ុនប្ដឹងសុំភាពធនក្ស័យ – **ហើយហ៊ានប្រថុយអាចឃើញការវិនាសបាត់បង់អត្ថប្រយោជន៍ទាំងអស់របស់អ្នកនោះឡើយ** – ដោយគ្មានការព្យាយាមមុនសិន ដើម្បីឲ្យក្រុមហ៊ុនកែកញ្ចប់ចំណែកនៃការសុខចិត្តចុះញ៉មរបស់ខ្លួនឲ្យប្រសើរឡើង ។ ដោយសារមូលហេតុនេះ ហើយដោយព្រោះលទ្ធផលការបោះឆ្នោតលើកដំបូងជិតស្មើគ្នាពេក បានជាការបោះឆ្នោតលើកទីពីរ ទៅលើកញ្ចប់បានកែឲ្យប្រសើរឡើង ដែលក៏មានបញ្ចូលក្នុងការសុខចិត្តចុះញ៉មពីក្រុមហ៊ុន សំរាប់ការចរចានៅលើកក្រោយទៀត ។

**UNITE HERE**